Public Health
Seattle & King County

# ការចាក់ថ្នាំវ៉ាក់សាំងបង្ការ (ជំងឺគ្រុនផ្តាសាយជ្រូក) H1N1 សម្រាប់ស្ត្រីមានផ្ទៃពោះ

**ខ្ញុំមានផ្ទៃពោះ។ តើខ្ញុំគួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 ទេ?**
ត្រូវហើយ! ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង គឺជាវិធីល្អបំផុតដើម្បីការពារខ្លួនអ្នក និងកូនរបស់អ្នកពីជំងឺគ្រុនផ្តាសាយឆ្លង។ ស្ត្រីមានផ្ទៃពោះ គួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 និងថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវ។

**ហេតុអ្វីខ្ញុំគួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1?**
ការចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងគឺមានសារសំខាន់ណាស់សម្រាប់ស្ត្រីមានផ្ទៃពោះ ដោយសារតែពួកគាត់ងាយប្រឈមមុខយ៉ាងខ្លាំងនឹងការទទួលរងនូវជំងឺធ្ងន់ធ្ងរបើពួកគាត់មានជំងឺគ្រុនផ្តាសាយឆ្លង។ ស្ត្រីមានផ្ទៃពោះនៅសហរដ្ឋអាមេរិក បានស្លាប់ដោយសារជំងឺគ្រុនផ្តាសាយឆ្លង H1N1 ។

**តើថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 មានសុវត្ថិភាពចំពោះខ្ញុំ និងកូនរបស់ខ្ញុំទេ?**
ត្រូវហើយ! ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 នឹងមានសុវត្ថិភាពដូចការចាក់ថ្នាំបង្ការជំងឺគ្រុនផ្តាសាយតាមរដូវដែរ។ ការចាក់ថ្នាំបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវមានសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះ និងទារក។ ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 ត្រូវបានគេធ្វើតេស្ត ដើម្បីសុវត្ថិភាពដូចថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវដែរ។

**តើថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 មានជាតិគីមីទេ?**
ថ្នាំវ៉ាក់សាំងបង្ការដែលមានសារធាតុ ធីមីរ៉ូសាល (thimerosal) មានសុវត្ថិភាពចំពោះស្ត្រីមានផ្ទៃពោះ និងកូនរបស់ពួកគាត់។ ការចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង ដោយមិនមានសារធាតុ ធីមីរ៉ូសាល (thimerosal) មួយចំនួនអាចមិនមានសុវត្ថិភាពទេ បើអ្នកមិនទៅ (ពិគ្រោះយោបល់ជាមួយអ្នក ផ្តល់សេវាថែទាំសុខភាព)។ វាមានសុវត្ថិភាពចំពោះអ្នកដែលបានចាក់ថ្នាំវ៉ាក់សាំងបង្ការដែលមាន ឬមិនមានសារធាតុ ធីមីរ៉ូសាល (thimerosal)។

**តើខ្ញុំត្រូវចាក់ថ្នាំបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 និងជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវទេ?**
ត្រូវហើយ! ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវ មិនអាចការពារអ្នកប្រឆាំងនឹងជំងឺផ្តាសាយឆ្លង H1N1 បានទេ។ ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 ក៏មិនអាចការពារអ្នកប្រឆាំងនឹងជំងឺគ្រុនផ្តាសាឆ្លងតាមរដូវបានដែរ។ អ្នកត្រូវចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងពីរដងដាច់ដោយឡែកពីគ្នា ដើម្បីការពារអ្នក និងកូនអ្នកពីជំងឺគ្រុនផ្តាសាយឆ្លង H1N1 និងជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវ។ អ្នកអាចចាក់ថ្នាំវ៉ាក់សាំងទាំងពីរប្រភេទក្នុងពេលតែមួយបាន។ ស្ត្រីមានផ្ទៃពោះគួរចាក់ថ្នាំបង្ការជំងឺគ្រុន ផ្តាសាយឆ្លងទាំងពីរឱ្យបានឆាប់តាមដែលអាចធ្វើបាន។

**តើខ្ញុំគួរចាក់ថ្នាំវ៉ាក់សាំងប្រភេទណា?**
ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងមានពីរប្រភេទ។ ស្ត្រីមានផ្ទៃពោះគួរចាក់ថ្នាំ "ថ្នាំចាក់បង្ការជំងឺគ្រុនផ្តាសាយឆ្លង" ដោយប្រើម្ជុលចាក់ដៃធម្មតា។ ស្ត្រីមានផ្ទៃពោះមិនអាចប្រើថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងផ្សេងទៀត - ដូចជាថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាឆ្លងបាញ់ចូលតាមច្រមុះទេ។

**តើប្រតិកម្មត្រឡប់ពីថ្នាំដែលអាចកើតមាននៃថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 មានអ្វីខ្លះ?**
មនុស្សភាគច្រើនមិនមានប្រតិកម្មត្រឡប់ពីថ្នាំទេ។ បើមានប្រតិកម្មត្រឡប់ពីថ្នាំកើតឡើង ពួកគាត់ស្ទើតែមិនអាចទ្រាំបាន។ ជាធម្មតា ប្រតិកម្មត្រឡប់ពីថ្នាំកើតមានភ្លាមៗ បន្ទាប់ពីចាក់ថ្នាំរួច និងមានរយៈពេល 1-2 ថ្ងៃ។ ប្រការទាំងនេះ រួមមានជំងឺគ្រុនក្តៅ ឈឺ ឈឺចាបខ្លាំង មានពណ៌ក្រហម ឬហើមតិចតួចត្រង់កន្លែងចាក់ថ្នាំ។ ពេលប្រើថ្នាំពេទ្យ ប្រតិកម្មអាឡែកហ្ស៊ីកើតឡើងតិចតួចណាស់។ កម្រមានបញ្ហាធ្ងន់ធ្ងរកើតឡើងនៅពេលចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងណាស់។ គ្រោះថ្នាក់បណ្តាលពីថ្នាំវ៉ាក់សាំងបង្ការមានតិចតួចជាងគ្រោះថ្នាក់បណ្តាលពីជំងឺគ្រុនផ្តាសាយឆ្លង។ អ្នកមិនគួរចាក់ថ្នាំវ៉ាក់សាំងបង្ការទេ បើមានអាឡែកហ្ស៊ីធ្ងន់ធ្ងរ ជាមួយស៊ុត ឬសារធាតុផ្សេងៗទៀតដែលមានក្នុងថ្នាំវ៉ាកសាំងបង្ការ។

**តើកូនរបស់ខ្ញុំអាចចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 បានទេ?**
កុមារដែលមានអាយុតិចជាង 6 ខែមិនអាចចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងបានទេ។ មនុស្សដែលរស់នៅជាមួយកុមារ ឬអ្នកមើលថែកុមារដែលមានអាយុតិចជាង 6 ខែគួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវ និងចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 ដើម្បីការពារទារកដែលទើបនឹងកើតពីជំងឺគ្រុនផ្តាសាយឆ្លង។

**តើខ្ញុំត្រូវចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 នៅឆ្នាំ 2009 នេះប៉ុន្មានដង?**
ស្ត្រីមានផ្ទៃពោះ និងមនុស្សផ្សេងទៀតដែលមានអាយុលើស 10 ឆ្នាំត្រូវចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1 តែម្តងប៉ុណ្ណោះ។

**តើខ្ញុំអាចធ្វើអ្វីបានទៀតដើម្បីការពារខ្លួនខ្ញុំ និងកូនរបស់ខ្ញុំ?**

- មនុស្សទាំងអស់ដែលអ្នករស់នៅជាមួយគួរចាក់ថ្នាំវ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយឆ្លងតាមរដូវ និងថ្នាំវ៉ាក់សាំបង្ការជំងឺគ្រុនផ្តាសាយឆ្លង H1N1មុនពេលទារកកើត។
- លាងដៃជាមួយសាប៊ូឱ្យបានញឹកញាប់។ បើគ្មានសាប៊ូ សូមប្រើវត្ថុដែលមានជាតិអាកុល។
- ហាមជូតភ្នែក ច្រមុះ ឬមាត់។ មេរោគអាចឆ្លងតាមវិធីនេះបាន។
- កុំនៅជិតអ្នកជំងឺ។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅ www.kingcounty.gov/health/h1n1 ឬទាក់ទងទូរស័ព្ទទាន់ហេតុការណ៍លេខ 877-903-5464, 24 ម៉ោង/ថ្ងៃ (អង់គ្លេស និងខ្មែរ) ។